



勞工處
Labour Department
1/2019


# សូមជ្រើសរើសទីភ្នាក់ងារមុខរបរ ដោយប្រុងប្រយ័ត្ន និងម៉ត់ចត់ -

## សូមប្រុងប្រយ័ត្នចំពោះការបោកបញ្ឆោតតាមរយៈការស្វែងរកការងារ





勞工處
Labour Department
Khmer Version 柬埔寨文版本

នៅពេលស្រ្តីជំនួយការតាមផ្ទះជាជនជាតបរទេស (FDHs) ប្រើប្រាស់សេវាកម្មរបស់ទីភ្នាក់ងារមុខរបរ (EAs) នៅហុងកុងដើម្បីគាំពារសិទ្ធិរបស់ខ្លួន ពួកគេគួរតែស្វែងយល់ពីចំណុចដែលចែងដូចខាងក្រោម៖



# នៅពេលជ្រើសរើសទីភ្នាក់ងារមុខរបរ (EA)




ជ្រើសរើសយកតែសេវាកម្មដាក់ឱ្យធ្វើការដែលបានផ្តល់ដោយទីភ្នាក់ងារមុខរបរ (EAs) ដែលចុះបញ្ជី ឬទទួលអាជ្ញាប័ណ្ណតែប៉ុណ្ណោះ។ សូមចូលពិនិត្យមើលតាមអ៊ីនធឺណេត នូវបញ្ជីទីភ្នាក់ងារមុខរបរ (EAs) ដែលមានអាជ្ញាប័ណ្ណត្រឹមត្រូវ និងចេញដោយនាយកដ្ឋានការងារ (LD) នៅគេហទំព័រទីភ្នាក់ងារមុខរបរ (EA) (www.eaa.labour.gov.hk)។

នាយកដ្ឋានការងារ LD បានប្រកាសដាក់ឱ្យប្រើនូវក្រឹត្យក្រមក្នុងការអនុវត្តសម្រាប់ទីភ្នាក់ងារមុខរបរ (EAs) (ហៅកាត់ថា"ក្រឹត្យក្រម")។ ដើម្បីធ្វើជាឯកសារយោង ដល់ក្រឹត្យក្រមនេះ សម្រាប់អ្វីដែលត្រូវធ្វើនិងអ្វីដែលមិនត្រូវធ្វើ របស់ទីភ្នាក់ងារមុខរបរ (EAs)។ ក្រឹត្យក្រមនេះក៏អាចរកបាន នៅគេហទំព័រទីភ្នាក់ងារមុខរបរ (EA) ផងដែរ។




ពិនិត្យមើលឱ្យច្បាស់ និងលម្អិតទាក់ទងឱកាសការងារដែលផ្តល់ដោយទីភ្នាក់ងារមុខរបរ (EAs) ជាពិសេសការងារនៅក្រៅប្រទេស។ ប្រសិនបើមានសំណួរ ឬចម្ងល់ សូមពិគ្រោះជាមួយអគ្គកុងស៊ុល (CG) នៃប្រទេសរបស់អ្នក ឬត្រួតពិនិត្យមើលជាមួយអគ្គកុងស៊ុលនៃប្រទេស ឬគោលដៅដែលអ្នកចង់ទៅ។




សូមកុំផ្តល់ព័ត៌មានមិនពិតនៅក្នុងកិច្ចសន្យាការងារស្តង់ដា (SEC) (ឧទាហរណ៍៖ ប្រាក់ឈ្នួលរបស់អ្នក អាស័យដ្ឋានទីកន្លែងការងាររបស់អ្នកជាដើម)។ អ្នកនឹងត្រូវទទួលទោសទៅតាមច្បាប់ ប្រសិនបើធ្វើដូច្នេះ។ សូមរក្សាទុកនូវច្បាប់ដើមកិច្ចសន្យាការងារ SEC ដែលអ្នកបានចុះហត្ថលេខា។




សូមកុំចុះហត្ថលេខាលើឯកសារ កិច្ចព្រមព្រៀង ឬកិច្ចសន្យាផ្សេងៗ ដែលអ្នកមិនទាន់យល់ច្បាស់ ឬមិនយល់ព្រមឡើយ។





សូមចូលទៅកាន់គេហទំព័រ FDH (www.fdh.labour.gov.hk) សម្រាប់រាល់ព័ត៌មានដែលទាក់ទងនឹងសិទ្ធិរបស់អ្នក និងការគាំពារនៅពេលធ្វើការនៅហុងកុង។

# កម្រៃសេវាដែលកំណត់ដោយទីភ្នាក់ងារមុខរបរ (EAs)




យោងទៅតាមច្បាប់ ទីភ្នាក់ងារមុខរបរ EAs នៅហុងកុង
ត្រូវបានអនុញ្ញាតឱ្យគិតកម្រៃសេវាដោយមិនច្រើនជាង១០%នៃប្រាក់ខែដំបូងដែលអ្នកបានទទួលបានដោយចាត់ជាកម្រៃជើងសារ (ឧទាហរណ៍៖ កម្រៃជើងសារដែលបានកំណត់) ។ ការបង់ថ្លៃសេវានេះនឹងគិត
បន្ទាប់ពីអ្នកទទួលបានប្រាក់ខែដំបូងរបស់អ្នក ដោយអ្នកមិនត្រូវបង់ថ្លៃសេវាមុនទទួលបានប្រាក់ខែដំបូងឡើយ។




ក្នុងលក្ខខ័ណ្ឌណាក៏ដោយ ទីភ្នាក់ងារមុខរបរ (EAs) មិនត្រូវគិតកម្រៃណាមួយពីអ្នក ដោយផ្ទាល់ ឬដោយប្រយោល ដែលទាក់ទងនឹងការដាក់ឱ្យធ្វើការ ក្រៅពីកម្រៃជើងសារដែលបានកំណត់នោះឡើយ។




តែងតែសួររកវិក័យបត្រទាក់ទងរាល់ការបង់ប្រាក់ណាមួយទៅឱ្យទីភ្នាក់ងារមុខរបរ (EAs) ។ វានឹងកាន់តែប្រសើរ ប្រសិនបើអ្នកបង់ ឬផ្ទេរប្រាក់ដោយផ្ទាល់ទៅគណនីក្រុមហ៊ុនរបស់ទីភ្នាក់ងារមុខរបរ EA ដូចនេះ អ្នកអាចទទួលកំណត់ត្រានៃការបង់ប្រាក់។ សូមជៀសវាងការផ្ទេរប្រាក់ទៅក្នុងគណនីផ្ទាល់ខ្លួនរបស់បុគ្គលិកទីភ្នាក់ងារមុខរបរ ឬបង់ជាសាច់ប្រាក់ដោយផ្ទាល់ទៅឱ្យពួកគេ។ សូមកុំបង់ប្រាក់ទៅឱ្យទីភ្នាក់ងារមុខរបរ EAs ប្រសិនបើពួកគេបដិសេធមិនព្រមចេញវិក័យបត្រអោយអ្នក។




សូមកុំខ្ចីប្រាក់ពីក្រុមហ៊ុន ឬភ្នាក់ងារផ្តល់សេវាកម្មហិរញ្ញវត្ថុណាមួយ ដើម្បីទូទាត់ថ្លៃសេវាកម្មដល់ក្រុមហ៊ុនសេវាកម្មស្វែងរកការងារធ្វើ EAs ទោះជាត្រូវបានស្នើសុំឬណែនាំដោយក្រុមហ៊ុនសេវាកម្មស្វែងរកការងារធ្វើក៏ដោយ EAs។

# ចំនុចផ្សេងៗទៀតដែលត្រូវចំណាំ



អ្នកត្រូវបំពេញកាតព្វកិច្ចតែការងារក្នុងផ្ទះឱ្យនិយោជករបស់អ្នក ហើយធ្វើការនៅក្នុងទីតាំងអាស័យដ្ឋានរបស់និយោជកអ្នក ដែលបានបញ្ជាក់នៅក្នុងកិច្ចសន្យាការងារស្តង់ដា SEC តែប៉ុណ្ណោះ ។ អ្នកមិនត្រូវបានអនុញ្ញាតធ្វើការឱ្យបុគ្គលណាម្នាក់ (បូករួមទាំងនិយោជករបស់អ្នក) នៅទីតាំងក្រៅពីអាស័យដ្ឋានដែលនិយោជករបស់អ្នកបានចែងនៅក្នុងកិច្ចសន្យាការងារស្តង់ដា SECនោះឡើយ បើទោះជានិយោជករបស់អ្នក ឬទីភ្នាក់ងារមុខរបរ EA របស់អ្នក ផ្តល់ការអនុញ្ញាត ឬស្នើសុំឱ្យអ្នកធ្វើតាមដូច្នេះក៏ដោយ។




គ្មានបុគ្គលណាម្នាក់ (ដូចជាទីភ្នាក់ងារមុខរបរ EAs និងនិយោជករបស់អ្នក) មានសិទ្ធដកហូតទ្រព្យសម្បត្តិផ្ទាល់ខ្លួនរបស់អ្នក រួមទាំងលិខិតឆ្លងដែន កាតអត្តសញ្ញាណប័ណ្ណហុងកុង និងកិច្ចសន្យាសេវារកការឱ្យធ្វើ SEC ជាដើម ដោយគ្មានការយល់ព្រមរបស់អ្នកឡើយ។

# នៅពេលសិទ្ធិរបស់អ្នកត្រូវបានរំលោភបំពាន

ប្រសិនបើអ្នកសង្ស័យថា ទីភ្នាក់ងារមុខរបរ EA គិតថ្លៃសេវាកម្មពីអ្នក លើសពីការកំណត់ ឬទីភ្នាក់ងារមុខរបរ EA ដែលកំពុងប្រតិបត្តិការ គ្មានអាជ្ញាប័ណ្ណអនុញ្ញាតត្រឹមត្រូវ អ្នកគួរទំនាក់ទំនងទៅនាយកដ្ឋានការងារ LD តាមរយៈលេខទូរស័ព្ទ ២១១៥ ៣៦៦៧ រាល់ម៉ោងធ្វើការ ឬតាមរយៈអ៊ីម៉ែល ea-ee@labour.gov.hk ។ សូមរាយការណ៍ករណីរបស់អ្នកទៅកាន់នាយកដ្ឋានការងារ LD ភ្លាមៗជាបន្ទាន់។

សម្រាប់ការសាកសួរនិងពាក្យបណ្តឹង ទាក់ទងទៅនឹងការងារនៅក្នុងទីក្រុងហុងកុង សូមទូរសព្ទមកកាន់លេខទូរសព្ទសម្រាប់ពលករបរទេសធ្វើការតាមផ្ទះតាម 2157 9537។ (ខ្សែទូរសព្ទអាចហៅបានតាម "1823")




ប្រសិនបើអ្នកត្រូវបានទទួលរងនូវអំពើហឹង្សា និងការរំលោភបំពាន ឬកំពុងប្រឈមនឹងគ្រោះថ្នាក់ប៉ះពាល់ដល់សុវត្ថិភាពរបស់អ្នក សូមទំនាក់ទំនងទៅកាន់លេខ ៩៩៩ ដើម្បីទទួលបានសេវាកម្មសង្គ្រោះបន្ទាន់ពីប៉ូលីសភ្លាមៗ។







ប្រសិនបើអ្នកត្រូវបង្ខំអោយធ្វើការនៅទីតាំងផ្សេងពីទីក្រុងហុងកុង សូមទំនាក់ទំនងទៅកាន់នាយកដ្ឋានអន្តោប្រវេសន៍ តាមរយៈទូរស័ព្ទលេខ ២៨២៤ ៦១១១។

